# San Diego Unified School District Fact Sheet

## ច្បាប់អប់រំរដ្ឋ California

ដើម្បីលើកទឹកចិត្តសិស្សគ្រប់រូបធ្វើការសិក្សាអោយមានកំរិតខ្ពស់, សាលារៀនប្រចាំទីក្រុង San Diego (SDCS) បានបង្កើតច្បាប់មាតិការអប់រំ California (CDE) ដែលបញ្ជាក់អំពីគំរិះវិជ្ជា, ដំណើរការសិក្សា និងជំនាញដែលសិស្សត្រូវសិក្សាបានដល់កំរិតថ្នាក់របស់ខ្លួន។ សៀវភៅពត៌មានសំរាប់មាតាបិតារៀបចំឡើងដើម្បីជួយពន្យល់ដល់មាតាបិតាយល់អំពីច្បាប់អប់រំដែលត្រូវប្រើប្រាស់នៅក្នុងសាលារៀនរបស់យើង។ សៀវភៅពត៌មាននោះមាននៅក្នុងប្រព័ន្ធ CDE website: http://www.cde.ca.gov/ls/pf/pf/.

ច្បាប់អប់រំដ៏សំខាន់នេះចែងអំពី មាតិការដែលសិស្សត្រូវការសិក្សាអោយដល់កំរិតថ្នាក់របស់ខ្លួន (មត្តេយ្យដ្ឋាន-១២) នៅតាមមុខវិជ្ជាដូចតទៅ:

- ភាសា អង់គ្លេស
- គណិតសាស្ត្រ
- ប្រវត្តិសាស្ត្រ-សង្គមសាស្ត្រ
- វិទ្យាសាស្ត្រ
- ផ្នែកសិល្បះ: រាំ, ភ្លេង, កុន
- ការរៀនភាសា អង់គ្លេស
- កីឡា

### សង្ខេប

- ❖ ច្បាប់អប់រំ CDE បញ្ជាក់អំពី គំរិះវិជ្ជា, ដំណើរការសិក្សា និងជំនាញដែលសិស្សត្រូវសិក្សាបានដល់កំរិតថ្នាក់និមួយៗ។
- ❖ ច្បាប់អប់រំទាំងនេះរៀបចំឡើងដើម្បីអោយសិស្សទាំងអស់នឹងទទួលបាន ព្រមទាំងមានពេលវេលាគ្រប់គ្រាន់សិក្សា លើកលែងតែសិស្សមានបញ្ហាសិក្សា។
- ❖ សិស្សដែលបានប្រឡងវិញ្ញាសារខ្នាតអប់រំបានល្អប្រសើរតាមគម្រោងការច្បាប់អប់រំដែលកំរិតតាមការប្រឡងរបស់រដ្ឋ។
- ❖ ការបង្កើតច្បាប់អប់រំរដ្ឋក្រសួងអប់រំប្រចាំក្រុងគាំទ្រការផ្តោតយ៉ាងពង្រឹងការសិក្សាសិស្សអោយបានល្អគួរលាស់យ៉ាងល្អបំផុត។

មុខវិជ្ជាដែលមិនទាន់រាប់បញ្ចូលដោយច្បាប់ក្នុងរដ្ឋ មុខវិជ្ជាមានរួមដូចជា: វិជ្ជាអប់រំផ្នែកសុខភាព, ភាសាពិភពលោក, ច្បាប់គំរូក្រសួងអប់រំប្រចាំក្រុង, ការប្រឡង, និងផ្នែកគ្រប់គ្រងកំពុងរៀបចំជាមួយបុគ្គលិកជំនាញការផ្នែកកម្មវិធីសិក្សា, បុគ្គលិកសាលារៀន, មាតាបិតា, និងសមាជិកសហគមន៍ដើម្បីបង្កើតច្បាប់មាតិការក្រសួងអប់រំប្រចាំក្រុងអោយស្របតាមគម្រោងការអប់រំរដ្ឋ។

មាតិការសិក្សានេះរៀបចំឡើងជាមួយសិស្សទាំងអស់មានគំនិតហើយសង្ឃឹមថា អាចផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សិស្សសិក្សា លើកលែងតែសិស្សមួយចំនួនតូចដែលមានបញ្ហាសិក្សា។ ពត៌មានពិសេសស្តីអំពី ច្បាប់អប់រំមុខវិជ្ជាសិក្សានិមួយៗ និងកំរិតថ្នាក់សិក្សាមាននៅក្នុងប្រព័ន្ធ website របស់ CDE: http://www.cde.ca.gov/be/st/ss/.

កម្មវិធីសិក្សារបស់ក្រសួងអប់រំប្រចាំក្រុង, កំរិតការប្រឡងរបស់សិស្ស, សៀវភៅមេរៀន, សម្ភារះបង្រៀន, ព្រមទាំងការបង្កើតមេរៀនឯកទេសគឺសម្របឲ្យស្មើនឹងច្បាប់អប់រំ។ ការធ្វើនេះគឺពិនិត្យមើលឲ្យបានច្បាស់លាស់ថា ផលប្រយោជន៍ និងគំរិះវិជ្ជាសិស្សតម្រូវតាមការសិក្សានៅតាមបន្ទប់រៀនសិស្ស ហើយមានការជាប់ទាក់ទងនឹងការប្រឡងរបស់រដ្ឋដែលសិស្សត្រូវប្រឡងជាប្រចាំឆ្នាំ។ វិញ្ញាសារប្រឡងជាចំបាច់របស់រដ្ឋធ្វើឡើងដើម្បីជួយវាស់កំរិតការសិក្សារបស់សិស្សដែលមានការជាប់ទាក់ទងនឹងការសិក្សាឲ្យបានដល់គោលការច្បាប់សិក្សា។ ពត៌មានបន្ថែមស្តីអំពីការប្រឡងវិញ្ញាសារសិស្សមាននៅក្នុងប្រព័ន្ធ website របស់ក្រសួងអប់រំប្រចាំក្រុង: http://www.sandi.net/indices/testscores.html.

ច្បាប់អប់រំបញ្ជាក់ច្បាស់លាស់ថា ក្រសួងអប់រំ SDCS ដូចនឹងសាលារៀនទូទៅក្នុងរដ្ឋ ត្រូវតែផ្តល់កម្មវិធីអប់រំឲ្យបានខ្ពស់ដល់សិស្ស។ ច្បាប់អប់រំឆ្លើយនឹងសំនួរថា " តើកូនរបស់ខ្ញុំត្រូវរៀនអំពីអ្វីខ្លះ? " ដើម្បីវាស់កំរិតវិជ្ជា, របៀបសិក្សា និងជំនាញការសិក្សាសិស្សម្នាក់ៗ។ តាមច្បាប់អប់រំនេះ ក្រសួងអប់រំប្រចាំក្រុងអាចធ្វើការគាំទ្រអោយល្អប្រសើរ និងពង្រឹងការសិក្សាសិស្ស ពេលគេធ្វើការពង្រឹងកម្មវិធីសិក្សា និងពង្រឹងវិធីប្រឡងដើម្បីឲ្យសិស្សសិក្សាបានល្អគួរលាស់។ ពត៌មានបន្ថែម សូមបើប្រព័ន្ធ webpage របស់ច្បាប់អប់រំ, ការប្រឡងស្រាវជ្រាវ និងផ្នែកគ្រប់គ្រងសាលារៀន: http://www.studata.sandi.net/saa.